

គោលនយោបាយសង្ខេប

# កសិរុក្ខកម្មក្នុងតំបន់អាស៊ីអាគ្នេយ៍៖
## ការតភ្ជាប់ចំណែកព្រៃឈើ-កសិកម្មសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព

World Agroforestry

AWG-SF
ASEAN Working Group on Social Forestry

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Agency for Development
and Cooperation SDC

asean

រៀបចំដោយកម្មវិធីរបស់មជ្ឈមណ្ឌលកសិរុក្ខកម្មពិភពលោកអាស៊ីអាគ្នេយ៍ (World Agroforestry Southeast Asia Regional Program)
រួមសហការជាមួយបណ្តាញព្រៃឈើសង្គមអាស៊ាន (ASEAN Social Forestry Network)

World Agroforestry Policy Brief No. 97

*រូបភាព៖ World Agroforestry/Meine van Noordwijk*

គោលនយោបាយសង្ខេប

# កសិរុក្ខកម្មក្នុងតំបន់អាស៊ីអាគ្នេយ៍៖

## ការតភ្ជាប់ចំណែកព្រៃឈើ-កសិកម្មសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព

World Agroforestry

AWG-SF
ASEAN Working Group on Social Forestry

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Agency for Development
and Cooperation SDC

asean

រៀបចំដោយកម្មវិធីរបស់មជ្ឈមណ្ឌលកសិរុក្ខកម្មពិភពលោកអាស៊ីអាគ្នេយ៍ (World Agroforestry Southeast Asia Regional Program)
រួមសហការជាមួយបណ្តាញព្រៃឈើសង្គមអាស៊ាន (ASEAN Social Forestry Network)

# បញ្ជីពាក្យកាត់ និងពាក្យបំព្រួញ

| | |
|---|---|
| **AMS** | (ASEAN Member State) រដ្ឋជាសមាជិកអាស៊ាន |
| **ASEAN** | (Association of Southeast Asian Nations) សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ |
| **ASFCC** | (ASEAN-Swiss Partnership on Social Forestry and Climate Change) ភាពជាដៃគូរអាស៊ាន-ស្វីសស្តីអំពីព្រៃឈើសង្គម និងការប្រែប្រួលអាកាសធាតុ |
| **AWG-SF** | (ASEAN Working Group on Social Forestry) បណ្តាញព្រៃឈើសង្គមអាស៊ាន |

អ្នកដឹកនាំថ្នាក់ជាតិ ដែលបានអនុម័តគោលនយោបាយគោលដៅអភិវឌ្ឍន៍ប្រកបដោយ និរន្តរភាពទាំង 17 ចំណុច និងបានចុះហត្ថលេខាជាបន្តបន្ទាប់លើកិច្ចព្រមព្រៀងអាកាសធាតុទីក្រុងប៉ារីស ដើម្បីយល់ព្រមទៅនឹងអភិក្រមរួមពីគ្រប់គោលនយោបាយបច្ចុប្បន្នដាច់ដោយឡែកៗពីគ្នា។ ដំណោះស្រាយមិនគ្រប់ជ្រុងជ្រោយដែលបណ្តាលឲ្យកើតមានបញ្ហាកាន់តែធំឡើងនៅគ្រប់ទីកន្លែង គឺពុំអាចទទួលយកបានទៀតឡើយ។ ក្នុងវិស័យប្រើប្រាស់ដីធ្លី ប្រវត្តិសាស្ត្រ និងស្ថាប័នផ្សេងៗគ្នាទាំងឡាយក្នុងការងារកសិកម្មនិងព្រៃឈើ មិនអាចធ្វើការរួមបញ្ចូលគ្នាបានឡើយ។ កសិរុក្ខកម្មអាចជួយជាគោលគំនិតរួម ដើម្បីតភ្ជាប់វិស័យនានានៅក្នុងទស្សនៈដែលមានលក្ខណៈរួមគ្នាមួយ។
រដ្ឋជាសមាជិកអាស៊ាន មានឱកាសប្រើប្រាស់គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព
ការបញ្ចូលគោលនយោបាយអាកាសធាតុ និងការដាក់ចេញនូវយុទ្ធសាស្ត្រថ្មីសម្រាប់វិស័យស្បៀងអាហារ កសិកម្ម និងព្រៃឈើរបស់អាស៊ាន ដើម្បីបង្កើតឲ្យបាននូវឱកាសជោគជ័យស្មើៗគ្នា។ តាមរយៈការរួមបញ្ចូលកសិកម្ម និងព្រៃឈើទៅជាការប្រើប្រាស់ដី ការយកចិត្តទុកដាក់អាចនឹងផ្តោតទៅលើការបំពេញមុខងារ ជាជាងទម្រង់ការក្នុងការសម្រេចនូវពហុមុខងារគម្របព្រៃឈើ និងជួយដល់ការបន្សុំា ការកាត់បន្ថយ និងសេវាកម្មអេកូឡូស៊ី។

| ល.រ | លទ្ធផលនៃការសិក្សាសំខាន់ៗ | ការអនុវត្តគោលនយោបាយ |
|---|---|---|
| 1 | ពាក្យថា "ព្រៃ" និង "ព្រៃឈើ" ត្រូវបានផ្តល់អត្ថន័យផ្សេងគ្នាពីពាក្យថា "កសិករ" និង "កសិកម្ម" ក្នុងច្បាប់ បទបញ្ញត្តិ ស្ថាប័ន ការអប់រំ និងទិដ្ឋភាពជាច្រើនទៀតនៃអភិបាលកិច្ច។ ជាញឹកញាប់ត្រូវបានគេមើលឃើញថាមានលក្ខណៈផ្ទុយគ្នា និងមានលក្ខណៈជាដៃគូប្រកួតប្រជែងគ្នាទៅវិញ។ | និយមន័យជាក់លាក់នៃពាក្យ "ព្រៃ" មានសារៈសំខាន់សម្រាប់បញ្ញត្តិនានាស្តីពីគោលនយោបាយដូចជា ការបាត់បង់ព្រៃឈើ ការដាំព្រៃឈើឡើងវិញ និងកសិរុក្ខកម្ម ការធានាគ្មានការបាត់បង់ព្រៃឈើ REDD+ និងសូចនាករជាច្រើនទៀតរបស់គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។ |
| 2 | នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ក្នុងចំណោមផ្ទៃដីកសិកម្មចំនួន 77% គឺមានគម្រព្រៃឈើយ៉ាងហោចណាស់ 10% ហើយក្នុងចំណោមផ្ទៃដីកសិកម្មចំនួន 47% យ៉ាងហោចណាស់ក៏មានគម្របព្រៃឈើចំនួន 30% ផងដែរ។ បើផ្អែកតាមលក្ខណៈវិនិច្ឆ័យទៅលើប្រព័ន្ធអេកូឡូស៊ី ជាជាងលក្ខណៈវិនិច្ឆ័យតាមស្ថាប័ននីមួយៗនោះ ផ្នែកជាច្រើនទៀតនៃទិដ្ឋភាពទាំងនេះ អាចត្រូវបានចាត់ទុកថាជា "ព្រៃ"។ | ដើមឈើ គឺជាផ្នែកទូទៅមួយនៃរូបភាពទេសភាពកសិកម្ម តំបន់ជាយក្រុង និងទីក្រុង ដែលផ្តល់នូវ អត្ថប្រយោជន៍សាធារណៈជាច្រើន។ ដើមឈើទាំងនេះ ត្រូវការគោលនយោបាយគាំទ្រដូចគ្នាទៅនឹងការគាំទ្រឈើទាំងនោះនៅក្នុងព្រៃដែរ។ |
| 3 | កសិរុក្ខកម្មដែលបានតភ្ជាប់រវាងកសិកម្មនិងព្រៃឈើ បានវិវត្តន៍ប្រែប្រួលពីបច្ចេកវិទ្យាវិភាគកម្រិតចំណែកដីនីមួយៗ ទៅក្នុងការវិភាគរូបភាពទេសភាពទូលំទូលាយ នៃភាពស៊ីសង្វាក់គ្នារវាងព្រៃឈើ-កសិកម្ម និងដំណើរផ្លាស់ប្តូររបស់វា។ គោលគំនិតពិស្តារនៃ "កសិកម្ម+ព្រៃឈើ" ក្នុងគោលនយោបាយសុខដុមនីយកម្ម បច្ចុប្បន្ននេះកំពុងលេចចេញនូវជម្រើសជាច្រើនដែលអាចសម្រេចបាន។ | បណ្តាប្រទេសមួយចំនួនបានបង្កើតគោលនយោបាយកសិរុក្ខកម្ម ដែលមិនបានកំណត់ច្បាស់រវាងព្រៃឈើ និងកសិរុក្ខកម្ម ឬរវាងកសិរុក្ខកម្ម និងកសិកម្មឡើយ ប៉ុន្តែបែជាផ្អែកទៅលើបច្ចុប្បន្នភាពនៃមុខងាររបស់សាធារណៈ និងឯកជន ព្រមទាំងតម្លៃនិងផលប្រយោជន៍ពាក់ព័ន្ធទៅនឹងប្រភេទផ្សេងៗគ្នានៃគម្របព្រៃឈើទៅវិញ។ |
| 4 | ការរួមបញ្ចូលគ្នានៃដើមឈើ និងកសិរុក្ខកម្មក្នុងដែនរូបភាពទេសភាពកសិកម្មអាចរួមចំណែកដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពជាច្រើន។ | ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព តម្រូវឲ្យមានការយកចិត្តទុកដាក់លើការបំពេញមុខងារជាជាងទៅលើទម្រង់ការ។ អភិក្រមកសិកម្ម+ព្រៃឈើដែលមានលក្ខណៈបុរទាក់ក្រឡាគ្នា នៅលើរូបភាពទេសភាពនានា និងក្នុងគោលនយោបាយសុខដុមនីយកម្ម ផ្តល់ឱកាសក្នុងការតភ្ជាប់ចំណែកនានាដែលមានស្រាប់។ |

# 1. ព្រៃ និងព្រៃឈើ ត្រូវបានផ្តល់អត្ថន័យផ្សេងគ្នា ដោយប្រៀបធៀបទៅនឹងកសិករនិងកសិកម្ម

ក្នុងច្បាប់ បទបញ្ញត្តិ ស្ថាប័ន ការអប់រំ និងទស្សនៈជាច្រើនទៀតនៃអភិបាលកិច្ចបង្ហាញថា ការប្រើប្រាស់ដីកសិកម្មដើម្បីផ្តល់ទំនិញនិងសេវាកម្មទីផ្សារក្នុងស្រុក គឺត្រូវបានគេឲ្យតម្លៃខុសគ្នាពីព្រៃឈើ បើទោះបីជាក្នុងករណីដែលដីកសិកម្មនោះ ផលិតនូវទំនិញ និងសេវាកម្មដូចគ្នា ឬប្រហាក់ប្រហែលគ្នាក៏ដោយ។ "គំលាតខុសគ្នាក្នុងកម្រិតស្ថាប័ន" នេះមានប្រវត្តិយូរលង់ណាស់មកហើយ។ នៅក្នុងប្រទេសអឺរ៉ុប បញ្ញត្តិនៃពាក្យថា "ព្រៃ" សំដៅលើតំបន់មួយដែលប្រជាពលរដ្ឋមិនអាចទៅដល់ ដែលត្រូវបានរក្សាទុកសម្រាប់តែការបរបាញ់ ការដកហូតយកផលឈើសម្រាប់ធ្វើនាវាសម្រាប់កងទ័ពជើងទឹក ឬសម្រាប់គោលបំណងផ្សេងទៀតរបស់រដ្ឋ។ ព្រៃនិងកសិដ្ឋានត្រូវបានគេមើលឃើញថាមានលក្ខណៈផ្ទុយគ្នា និងជាគូប្រកួតប្រជែងនឹងគ្នា។ ប្រពៃណីនេះ ត្រូវបានឆ្លុះបញ្ចាំងផងដែរតាមរយៈការអប់រំ និងវិទ្យាសាស្ត្រពាក់ព័ន្ធទៅនឹងព្រៃឈើ និងវិស័យកសិកម្ម ដែលមានលក្ខណៈដាច់ដោយឡែកពីគ្នា នាំឲ្យមានភាពខុសគ្នាផ្នែកវប្បធម៌ និងផ្នត់គំនិតដែលនៅតែបន្តកើតមានឡើងនៅទូទាំងពិភពលោក។




រូបភាព 1. បញ្ញត្តិស្តីពីព្រៃ ដោយផ្អែកលើគម្របព្រៃឈើ ធ្វើអន្តរកម្មជាមួយបញ្ញត្តិដទៃទៀតផ្អែកទៅតាមស្ថាប័ននានា (van Noordwijk and Minang 2009)

ក្នុងកិច្ចពិភាក្សាអំពីការប្រែប្រួលអាកាសធាតុ ព្រៃឈើ និងកសិកម្ម នៅតែត្រូវបានគេយកមកពិភាក្សាក្នុងប្រធានបទពីរផ្សេងគ្នា បើទោះបីជាទំនាក់ទំនងរវាងព្រៃឈើ និងកសិកម្មត្រូវបានគេមើលឃើញថា ជាចំណុចស្នូលចំបាច់សម្រាប់ការរៀបចំគោលនយោបាយនេះក៏ដោយ។ ទោះបីជាយ៉ាងណា នៅពេលដល់ដំណាក់កាលបង្កើតគោលនយោបាយ វាបង្ហាញឲ្យឃើញច្បាស់ថាមានភាពពិបាកក្នុងការកំណត់យកនិយមន័យ "ព្រៃឈើ" ឲ្យបានច្បាស់លាស់។  យោងតាមនិយមន័យរបស់អង្គការកសិកម្ម និងស្បៀងអាហារពិភពលោក (FAO 2000 2015) ដែលបានប្រើប្រាស់ទូទាំងពិភពលោកបានឲ្យនិយមន័យថា ដីដែលមានដើមឈើគ្រប់គ្រាន់អាចត្រូវបានគេហៅថា "ព្រៃ" ដរាបណាវាមិនមែនជាដីកសិកម្ម ឬជាតំបន់ទីក្រុងទេនោះ។ ដើម្បីជាប្រសិទ្ធិភាព អាចិភាពពិតជាមាន ភាពខុសគ្នាផ្នែកស្ថាប័ននៅក្នុងរូបភាពទេសភាពរបស់យើងរវាងដីដែលត្រូវបានគេចាត់ទុកជា "ព្រៃ" និងដីដែលមិនមែនជាព្រៃ គឺភាគច្រើនអាស្រ័យលើកត្តាប្រវត្តិសាស្ត្រ។ ការពិចារណាទៅលើពាក្យថា "គម្របព្រៃឈើ" អាចបញ្ជាក់ប្រាប់អំពីរឿងផ្សេងគ្នាតាមរយៈមុខងារដែលវាបានផ្តល់ឲ្យ។

# 2. គម្របព្រៃឈើលើដីកសិកម្មក្នុងតំបន់អាស៊ីអាគ្នេយ៍

តាមរយៈរូបភាពពីផ្កាយរណប ដើមឈើ និងគម្របព្រៃឈើ ត្រូវបានគេញែកចេញពីសារពើរុក្ខជាតិដទៃទៀត។ រូបភាពសង្ខេបនៃចំណែកផ្ទៃដីកសិកម្ម (មិនរួមបញ្ចូលអ្វីដែលប្រទេសនីមួយៗបានចុះបញ្ជីថាជា "ព្រៃ" ក្នុងមូលដ្ឋានទិន្នន័យ អន្តរជាតិ ដែលគ្រប់គ្រងដោយ FAO) ដែលមានកម្រិតនៃគម្របព្រៃឈើផ្សេងៗគ្នា (រូបភាព 2) បានបង្ហាញថា មួយភាគធំនៃផ្ទៃដីកសិកម្មដែលមាន "គម្របព្រៃឈើ" គ្រប់គ្រាន់ អាចត្រូវបានចាត់ទុកថាជា "ព្រៃ"។ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ក្នុងចំណោមផ្ទៃដីកសិកម្ម 77%  មានគម្របព្រៃឈើយ៉ាងហោចណាស់ចំនួន 10%  ហើយក្នុងចំណោមផ្ទៃដីកសិកម្ម 47% យ៉ាងហោចណាស់ ក៏មានគម្រព្រៃឈើ 30% ផងដែរ។

ផ្នែកនៃរូបភាពទេសភាពទាំងនេះ អាចត្រូវបានគេចាត់ទុកថាជា "ព្រៃ" បើផ្អែកទៅលើលក្ខណៈវិនិច្ឆ័យអេកូឡូស៊ីជាជាងផ្អែកលើលក្ខខណ្ឌវិនិច្ឆ័យផ្អែក ស្ថាប័ន (Zomer et al 2014)។ ភាគរយគម្របព្រៃឈើក្នុងតំបន់អាស៊ីអាគ្នេយ៍គឺមានកម្រិតខ្ពស់ ប៉ុន្តែជាធម្មតាតែងមានទំនាក់ទំនងទៅនឹងកម្រិតទឹកភ្លៀង (រូបភាព 2)។ ដីកសិកម្មនៅអាមេរិចកណ្ដាល មានគម្របព្រៃឈើក្នុងកម្រិតខ្ពស់ជាង។ គម្របព្រៃឈើស្ថិតនៅខាងក្រៅព្រៃគឺមានការប្រែប្រួលជាមួយនឹងការកើនឡើងនិងថយចុះគួរឲ្យកត់សម្គាល់នៅពេលធ្វើការវាយតម្លៃក្នុងរយៈជាង10ឆ្នាំ មកនេះ (រូបភាព 3)។




រូបភាព 2 គម្របឈើលើដីកសិកម្មចាត់ជាមុខងារមួយនៃបរិមាណទឹកភ្លៀង (Zomer et al 2014)




រូបភាព 3 បម្រែបម្រួលគម្របព្រៃឈើលើដីកសិកម្ម (មិនមែនព្រៃ) ក្នុងតំបន់អាស៊ីអាគ្នេយ៍ (Zomer et al 2016)

# 3. កសិរុក្ខកម្ម ជាស្ពានតភ្ជាប់រវាង "ព្រៃ" និង "កសិកម្ម"

បញ្ញត្តិនៃពាក្យកសិរុក្ខកម្ម (រូបភាព 4) បានវិវត្តចេញមកពីការរួមបញ្ចូលគ្នាកម្រិតចំណែកដីដែលមានដើមឈើ ដំណាំ និងសត្វចិញ្ចឹម ដូចជា "taungya" ក្នុងប្រទេសភូមា និង "tumpang sari" ក្នុងប្រទេសឥណ្ឌូនេស៊ី នៅក្នុងប្រព័ន្ធជាច្រើនទៀត ដែលមានតម្លៃសម្រាប់ធ្វើការផ្សព្វផ្សាយ ការកសាងសមត្ថភាព និងការសិក្សាស្រាវជ្រាវ។




រូបភាព 4៖ បញ្ញត្តិស្តីពីកសិរុក្ខកម្មដំបូងចាត់ដូចជាបច្ចេកវិទ្យាមួយ

បញ្ញត្តិស្តីពីកសិរុក្ខកម្មបច្ចុប្បន្ន បានរួមបញ្ចូលនូវអភិក្រមក្នុងកម្រិតរូបភាពទេសភាពមួយ (រូបភាព 5) ដែលរួមមាន "ដើមឈើលើដីកសិដ្ឋាន" និង "ការធ្វើចំការក្នុងព្រៃ" នៅពេលដែលបញ្ហាដូចជាសិទ្ធិ (ទាញយកព្រៃឈើ ការធ្វើផែនការ និងការធ្វើចំណាត់ថ្នាក់ប្រើប្រាស់ដី) និងទីផ្សារ (ការវិនិយោគ តម្រូវការសម្រាប់ផលិតផល ការលើកទឹកចិត្ត) គឺជាច្រកចូលដ៏មានសារៈសំខាន់សម្រាប់គោលនយោបាយដែលមានបំណងធ្វើការអភិវឌ្ឍឲ្យល្អប្រសើរបំផុត។




រូបភាព 5 កសិរុក្ខកម្ម បានទទួលយកនិងជួយឲ្យកើតមាននូវ អភិក្រមរូបភាពទេសភាពនៅពាក់កណ្តាលទសវត្សន៍ 1990

ដំណាក់កាលទីបីក្នុងការវិវត្តន៍នេះ តម្រូវឲ្យមានការរួមបញ្ចូលទូលំទូលាយបន្ថែមទៀតនូវ "កសិ+ព្រៃឈើ" (រូបភាព 6) ការធ្វើឲ្យមានសុខដុមនីយកម្មគោលនយោបាយ ដើម្បីឲ្យគោលនយោបាយទាំងនោះធ្វើប្រតិបត្តិការនៅគ្រប់សមាសភាពពេញលេញនៃអន្តរកម្មរវាងដើមឈើ-កសិករ-ព្រៃឈើ និងគាំទ្រដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពមួយចំនួនធំ។




រូបភាព 6 កសិ-បូក-ព្រៃឈើ ចាត់ដូចជាវិស័យគោលនយោបាយមួយ

ដូច្នេះ កសិរុក្ខកម្ម អាចដើរតួជាស្ពានតភ្ជាប់រវាងកសិកម្ម និងព្រៃឈើ និងផ្តល់នូវវិធីសាស្ត្រប្រើប្រាស់ដីរួមមួយ ដើម្បីសម្រេចគោលដៅនានាដែលគាំទ្រដល់គោលបំណងសេដ្ឋកិច្ចពិភពលោកប្រកបដោយនិរន្តរភាព (រូបភាព 7)។ វាបានផ្តល់កម្លាំងរុញច្រាន ដល់អ្នករៀបចំគោលនយោបាយដើម្បីធ្វើសកម្មភាពតាមរយៈការបង្កើតហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដែលអាចជួយរៀបចំឡើងវិញនូវអន្តរកម្មសាធារណៈ-ឯកជន ដើម្បីបង្កើតភាពជាដៃគូលើរូបភាពទេសភាពធំទូលាយ ដែលអាចសម្រេចបាននូវគោលបំណងពីរ គឺផ្នែកសុខុមាលភាពបរិស្ថាន និងកំណើនសេដ្ឋកិច្ច។ មហិច្ឆតាដើម្បីក្លាយជា "អាកាសជាតុឆ្លាត (climate smart)" គឺត្រូវជាប់ជាមួយ កសិរុក្ខកម្ម និងផ្តល់នូវថាមពលជម្រុញដើម្បីការផ្លាស់ប្តូរដែលចាំបាច់នានា។




រូបភាព 7. ដើមឈើគោលដៅអភិវឌ្ឍប្រកបដោយនិរន្តរភាព

# 4. កសិរុក្ខកម្មជាគោលគំនិតរួមបញ្ចូលគ្នាមួយដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍប្រកបដោយនិរន្តរភាព

នៅក្នុងគោលនយោបាយសង្ខេបថ្មីៗនេះ (van Noordwijk et al 2015) យើងបានសង្ខេបវិធីសាស្ត្របួនយ៉ាង ដែលកសិរុក្ខកម្មអាចជួយសម្រេចបានគោលដៅ៖

1. កសិរុក្ខកម្មជាប្រព័ន្ធប្រើប្រាស់ដី រវាងព្រៃឈើ និងកសិកម្មលើទីវាលចំហ ដោយមានការរួមបញ្ចូលគ្នានូវដើមឈើដំណាំ និងសត្វចិញ្ចឹមផងនោះ អាចផ្តល់នូវផលិតផល អត្ថប្រយោជន៍ និងសេវាកម្មជាច្រើនក្នុងពេលដំណាលគ្នា៖ អាហារដែលមានជីវជាតិ ថាមពលកកើតឡើងវិញ ទឹកស្អាត និងជីវចម្រុះ។
2. កសិរុក្ខកម្ម គឺជាពហុមុខងារនៃការប្រើប្រាស់ដីដែលមានប្រសិទ្ធិភាព បើតាមលក្ខណៈបច្ចេកទេសមានន័យថា អាចទទួលបានដីដែលមានតម្លៃសមាមាត្រខ្ពស់ជាង 1 ដែលជាវិធានការប្រកបដោយភាពជោគជ័យមួយនៅក្នុង ☒ប្រពលវប្បកម្មប្រកបដោយនិរន្តរភាព☒ ដែលអាចជួយកាត់បន្ថយគម្លាតទិន្នផលបាន។
3. កសិរុក្ខកម្ម អាចជាស្ថាប័នមួយដែលមានប្រសិទ្ធិភាព ដើម្បីឆ្លើយតបទៅនឹងការប្រកួតប្រជែងទាញយកធនធានដែលអាចជួយជំរុញឲ្យមានសមភាពយែនឌ័រ និងសមភាពសង្គម និងដើរតួជាប្រភពក្នុងការផ្តល់អំណាចដល់សហគមន៍។
4. កសិរុក្ខកម្ម ជាវប្បធម៌នៃការរួមបញ្ចូលគ្នាមួយនៅទូទាំងពហុមុខងាររូបភាពទេសភាព ដែលអាចបង្កើតចំណុចរួមគ្នារវាងគោលដៅផ្សេងៗគ្នា និងជួយឲ្យរួចចេញពីរណ្តៅនៃស្ថាប័នទាំងនោះ។

## ផ្លូវនៅខាងមុខ

ភាពខ្វះចន្លោះរវាងកសិកម្ម-ព្រៃឈើដែលមានស្រាប់ មានប្រវត្តិយូរលង់ណាស់មកហើយ។ ដោយផ្អែកតែលើការបែងចែកស្ថាប័នបច្ចុប្បន្ន កិច្ចពិភាក្សាតែមួយមុខ នឹងមិនអាចនាំឲ្យមានការផ្លាស់ប្តូរនោះទេ។ ការផ្លាស់ប្តូរ នឹងទាមទារឲ្យមានភាពជាអ្នកដឹកនាំនៅខាងលើ ដែលផ្តោតលើការបំពេញមុខងារជាជាងទម្រង់ការ៖ ដំណើរការពិតប្រាកដដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅតំបន់ជនបទ ដែលភាពក្រីក្រនៅតែមាន នឹងទាមទារនូវវិធីសាស្ត្រថ្មីនៃការរួមបញ្ចូលសិទ្ធិ ការផ្តល់ប្រាក់ឧបត្ថម្ភការយល់ដឹង (បច្ចេកទេស ជាតុចូល) និងការលើកទឹកចិត្ត (សមត្ថភាពមនុស្ស) ដែលគោលគំនិតកសិរុក្ខកម្មអាចគាំទ្របាន។ បើពុំមានការគោរពនូវសមិទ្ធផលពីវិស័យនានាពីអតីតកាលនោះទេ ☒ការសម្រុះសម្រួលថ្មី☒ នៅក្នុងទេសភាពគឺជាតម្រូវការចាំបាច់ ដើម្បីសម្រេចនូវមហិច្ឆតាដែលបានបញ្ជាក់ក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងកិច្ចព្រៀមព្រៀងដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ។

## អនុសាសន៍

នៅក្នុងផែនការដែលមានស្រាប់សម្រាប់វិស័យស្បៀងអាហារ កសិកម្ម និងព្រៃឈើរបស់អាស៊ាន មានឱកាសជាច្រើនក្នុងការប្រើប្រាស់ក្របខណ្ឌនៃគោលដៅ និងកិច្ចព្រមព្រៀងអាកាសធាតុទីក្រុងប៉ារីស ដើម្បីអនុម័តគោលនយោបាយកសិរុក្ខកម្មដើម្បីគាំទ្រការធ្វើសមាហរណកម្ម និងការគ្រប់គ្រងកសិកម្ម និងព្រៃឈើ ដូចជាការប្រើប្រាស់ដីជាមួយនឹងគម្របព្រៃឈើដែលមានពហុមុខងារ។ វិធានការជាក់លាក់ អាចនឹងពឹងផ្អែកទៅលើប្រវត្តិនៃស្ថាប័ន និងទំនាក់ទំនងបច្ចុប្បន្នរវាងកសិកម្ម និងព្រៃឈើនៅក្នុងរដ្ឋជាសមាជិកអាស៊ានខុសៗគ្នា។

# សម្រាប់ការអានបន្ថែម

Chazdon RL, Brancalion PH, Laestadius L, Bennett-Curry A, Buckingham K, Kumar C, Moll-Rocek J, Vieira ICG, Wilson SJ. 2016. When is a forest a forest? Forest concepts and definitions in the era of forest and landscape restoration. *Ambio* March:1–13. DOI:10.1007/s13280-016-0772-y.

[FAO] Food and Agriculture Organization of the United Nations. 2000. *FRA 2000: on definitions of forest and forest change*. Forest Resources Assessment Working Paper 33. Rome: Food and Agriculture Organization of the United Nations.

[FAO] Food and Agriculture Organization of the United Nations. 2015. *FRA 2015: terms and definitions*. Forest Resources Assessment Working Paper 180. Rome: Food and Agriculture Organization of the United Nations.

Leimona B, Lusiana B, van Noordwijk M, Mulyoutami E, Ekadinata A, Amaruzaman S. 2015. Boundary work: knowledge co-production for negotiating payment for watershed services in Indonesia. *Ecosystem Services* 15:45–62.

Mbow C, van Noordwijk M, Prabhu R, Simons AJ. 2014. Knowledge gaps and research needs concerning agroforestry's contribution to sustainable development goals in Africa. *Current Opinion in Environmental Sustainability* 6:162–170.

van Noordwijk M, Minang PA. 2009. *If we cannot define it, we cannot save it*. ASB Policy Brief 15. Nairobi: ASB Partnership for the Tropical Forest Margins. http://www.asb.cgiar.org/pdfwebdocs/ASBPB15.pdf.

van Noordwijk M, Minang PA, Hairiah K. 2015. Swidden transitions in an era of climate change. In: Cairns MF, ed. *Shifting cultivation and environmental change: indigenous people, agriculture and forest conservation*. Oxford, UK: Earthscan. pp 261–280.

van Noordwijk M, Mbow C, Minang PA. 2015. *Trees as nexus for Sustainable Development Goals (SDGs): agroforestry for integrated options*. Policy Brief 50. Nairobi: ASB Partnership for the Tropical Forest Margins.

Zomer RJ, Neufeldt H, Xu J, Ahrends A, Bossio DA, Trabucco A, van Noordwijk M, Wang M. 2016. Global tree cover and biomass carbon on agricultural land: The contribution of agroforestry to global and national carbon budgets. *Scientific Reports* 6:29987.

Zomer RJ, Trabucco A, Coe R, Place F, van Noordwijk M, Xu JC. 2014. *Trees on farms: an update and reanalysis of agroforestry's global extent and socio-ecological characteristics*. Working Paper 179. Bogor, Indonesia: World Agroforestry Centre (ICRAF) Southeast Asia Regional Program. DOI: 10.5716/WP14064.PDF.

# អ្នកនិពន្ធ

Meine van Noordwijk (m.vannoordwijk@cgiar.org)
Rodel Lasco (r.lasco@cgiar.org)

# ឯកសារយោងដែលត្រឹមត្រូវ

van Noordwijk M, Lasco R. 2018. *Agroforestry in Southeast Asia: bridging the forestry–agriculture divide for sustainable development* (in Khmer). Policy Brief no. 97. Agroforestry options for ASEAN series no. 1. Bogor, Indonesia: World Agroforestry (ICRAF) Southeast Asia Regional Program; Jakarta, Indonesia: ASEAN-Swiss Partnership on Social Forestry and Climate Change.

For more information, contact


**AWG-SF Secretariat**
Manggala Wanabhakti Building, Block VII, 4th Floor,
Jalan Gatot Subroto, Senayan, Jakarta 10270, Indonesia
Tel: +62-21-5703246, ext 478 - Fax: +62-21-5730136

**World Agroforestry (ICRAF)**
**Southeast Asia Regional Program**
Jl. CIFOR, Situ Gede, Sindang Barang, Bogor 16115
[PO Box 161, Bogor 16001] Indonesia
Tel: +(62) 251 8625415 | Fax: +(62) 251 8625416
Email: icraf-indonesia@cgiar.org
www.worldagroforestry.org/region/southeast-asia
blog.worldagroforestry.org


Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Agency for Development
and Cooperation SDC

**ASEAN Working Group on Social Forestry (AWG-SF)** is government-initiated network that aims to strengthen social forestry in Southeast Asia through the sharing of information and knowledge. AWG-SF established by the Association of Southeast Asian Nations (ASEAN) Senior Officials on Forestry (ASOF) in August 2005, linking government forestry policy makers directly with the civil society organizations, research organizations, academia, private sector, and all of whom share a vision of promoting social forestry policy and practices in ASEAN.

The **ASEAN-Swiss Partnership on Social Forestry and Climate Change (ASFCC)** is a Partnership Programme of ASEAN that aims to contribute to the ASEAN Mandate and Policy Framework through support for the ASEAN Working Group on Social Forestry and the ASEAN Multi sectoral Framework on Climate Change towards Food Security.